ទស្សនៈ អ្នកនិពន្ធ

វ៉ុល៤, លេខ២១, ថ្ងៃទី១ ខែមករា ឆ្នាំ២០២២

# ការបន្តវេនដើម្បីការផ្លាស់ប្តូរ: ករណីបណ្ឌិត ហ៊ុន ម៉ាណែត

បណ្ឌិត អ៊ុន ឃាង *

នៅក្នុងសន្និបាតប្រចាំឆ្នាំលើកទី៤៣ ប្រារព្ធធ្វើឡើងនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ គណកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជាបានបោះឆ្នោតគាំទ្របណ្ឌិត ហ៊ុន ម៉ាណែត ជាបេក្ខភាពនាយករដ្ឋមន្ត្រីក្នុងពេលអនាគតសម្រាប់គណបក្សប្រជាជនកម្ពុជា។ ការជ្រើសរើសនេះបានទាក់ទាញចំណាប់អារម្មណ៍ និងការរិះគន់ពីមជ្ឈដ្ឋានជាច្រើន។ អត្ថបទនេះមានគោលបំណងចូលរួមពិភាក្សាជុំវិញការជ្រើសរើសបេក្ខភាពរបស់បណ្ឌិត ហ៊ុន ម៉ាណែត ដោយផ្តោតទៅលើការចោទសួរថា តើហេតុអ្វីបានជាការជ្រើសរើសនេះមានសារៈសំខាន់ និងត្រឹមត្រូវសម្រាប់កម្ពុជា។

ទោះបីជាមានការរិះគន់ពីមជ្ឈដ្ឋានមួយចំនួននៅក្នុង និងក្រៅប្រទេសក្រោមការដឹកនាំរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងគណបក្សប្រជាជនកម្ពុជាក៏ដោយ ក៏ប្រទេសកម្ពុជាបានទទួលសន្តិភាព និងការអភិវឌ្ឍសេដ្ឋកិច្ចគួរកត់ឱ្យសម្គាល់។ ការសិក្សាស្រាវជ្រាវបានបង្ហាញថា សន្តិភាព គឺជាគន្លឹះនៃការអភិវឌ្ឍសេដ្ឋកិច្ច។ ប្រទេសដែលមានវិបត្តិនយោបាយ ឬសង្គ្រាមស៊ីវិល មិនត្រឹមតែមិនមានការអភិវឌ្ឍសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបណ្តាលអោយមានផលប៉ះពាល់ដល់ប្រទេសជិតខាងទៀតផង។ បន្ថែមលើនេះ ប្រសិនបើគ្មានកំណើនសេដ្ឋកិច្ចទេ ការអភិវឌ្ឍលើវិស័យដទៃទៀតក៏មិនអាចកើតឡើងបានដែរ។ ក្នុងកំឡុងពេលពីរទសវត្សរ៍កន្លងទៅនេះ កំណើនសេដ្ឋកិច្ច នៅប្រទេសកម្ពុជាមានអត្រាជាមធ្យម ៧ ភាគរយ នៅមុនការរាលដាលនៃជំងឺកូវីដ១៩។ យើងមិនអាចធ្វើការរៀបរាប់ពីសមិទ្ធិផលឱ្យបានអស់នោះទេ ប៉ុន្តែ ខ្ញុំគិតថាវាគ្រប់គ្រាន់ក្នុងការលើកយកភាពជោគជ័យពីរ មកបរិយាយនៅទីនេះ។ ភាពជោគជ័យទីមួយ គឺការលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធ។ នរណាម្នាក់ដែលមានវ័យចំណាស់គ្រប់គ្រាន់ដែលបានធ្វើដំណើរ និងរស់នៅក្នុងប្រទេសកម្ពុជាក្នុងទសវត្សរ៍ទី៨០ និង៩០ អាចចងចាំបានយ៉ាងច្បាស់ពីផ្លូវដែលពោរពេញដោយជង្ហុក ជិះសាឡាងដើម្បីឆ្លងកាត់ទន្លេ និងការដាច់ចរន្តអគ្គិសនីជាញឹកញាប់។ រឿងរ៉ាវទាំងនេះបានរំលងផុតទៅហើយសម្រាប់កម្ពុជានាពេលនេះ។ ភាពជោគជ័យទីពីរ ដែលគួរឱ្យកត់សម្គាល់នោះ គឺជាការធ្លាក់ចុះនៃភាពក្រីក្រនៅកម្ពុជា។ ជាសង្ខេប ការកាត់បន្ថយភាពក្រីក្រ និងការរីកចម្រើនផ្នែកហេដ្ឋារចនាសម្ព័ន្ធមិនអាចសម្រេចបាននោះទេ ប្រសិនបើគ្មានកំណើនសេដ្ឋកិច្ចជាបន្តបន្ទាប់។ ហើយកំណើននេះទៀតសោតក៏មិនអាចកើតឡើងបានដែរ ប្រសិនបើគ្មានការដឹកនាំល្អរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងថ្នាក់ដឹកនាំគណបក្សប្រជាជនដទៃទៀត។

ទោះបីជាមានជោគជ័យឥតគណនាក៏ដោយ ប៉ុន្តែ សម្តេច ហ៊ុន សែន កាន់តែមានវ័យចំណាស់ទៅហើយ។ ដូច្នេះ វាជាការចាំបាច់ដែលកម្ពុជាត្រូវការជ្រើសរើសអ្នកបន្តវេនដឹកនាំឱ្យបានរលូន។ ការផ្ទេរតំណែងដោយសន្តិភាព គឺមានសារៈសំខាន់ក្នុងការបន្តពង្រឹង និងពង្រីកសេដ្ឋកិច្ច និងសង្គមក្នុង

---

* **បណ្ឌិត អ៊ុន ឃាង** គឺជាសាស្ត្រាចារ្យផ្នែកវិទ្យាសាស្ត្រនយោបាយ នៅសាកលវិទ្យាល័យ Northern Illinois សហរដ្ឋអាមេរិក និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

*© រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។*

ខណៈដែលស្ថានភាពក្នុងស្រុក និងសកលមានការប្រែប្រួលយ៉ាងខ្លាំង។ ការវិវត្តនៅប្រទេសដទៃទៀត ដូចជា អេហ្ស៊ីប និងឥណ្ឌូណេស៊ី បានបង្ហាញយ៉ាងច្បាស់នូវគ្រោះថ្នាក់នៃកង្វះខាតនៃការគិតគូរឱ្យបានស៊ីជម្រៅទុកជាមុនក្នុងការផ្ទេរតំណែងពីជំនាន់មួយទៅជំនាន់មួយទៀត។ កង្វះខាតនេះបានបង្កឱ្យមានអស្ថិរភាពសង្គម និងផលប៉ះពាល់អវិជ្ជមានដល់សេដ្ឋកិច្ចរបស់ប្រទេសទាំងពីរនេះ។

ការជ្រើសរើសបណ្ឌិត ហ៊ុន ម៉ាណែត ជាបេក្ខភាពនាយករដ្ឋមន្ត្រីនាពេលអនាគត គឺជាជម្រើសដ៏ត្រឹមត្រូវមួយ។ ប៉ុន្តែ មជ្ឈដ្ឋានអ្នករិះគន់ក្នុង និងក្រៅប្រទេសបានចោទប្រកាន់ថា ដំណើរការនៃការតែងតាំងបណ្ឌិត ហ៊ុន ម៉ាណែត ជាបេក្ខភាពនាយករដ្ឋមន្ត្រីអនាគត គឺជាការចាក់ឬសនៃរាជវង្សនយោបាយគ្រួសារវាសដោយសម្តេច ហ៊ុន សែន។ ការវិភាគរបស់ខ្ញុំឃើញថា ដំណើរការនៃការតែងតាំងបណ្ឌិត ហ៊ុន ម៉ាណែត ជាបេក្ខភាពនាយករដ្ឋមន្ត្រីនាពេលអនាគត គឺបង្ហាញពីស្ថាប័ននីយកម្មរបស់គណបក្សប្រជាជនកម្ពុជា។ ស្ថាប័ននីយកម្ម និងឯកភាពផ្ទៃក្នុងដែលបានវិវត្តចាប់ពីទសវត្សរ៍នៃការតស៊ូប្រដាប់អាវុធប្រឆាំងនឹងរបបវាលពិឃាតខ្មែរក្រហម និងការតស៊ូប្រដាប់អាវុធក្នុងសង្គ្រាមស៊ីវិលបន្តបន្ទាប់ និងកិច្ចខិតខំប្រឹងប្រែងកសាងរដ្ឋចាប់តាំងពីឆ្នាំ១៩៧៩ រហូតដល់ចុងឆ្នាំ១៩៩០។ នៅក្នុងអំឡុងពេលនេះ ជាមួយនឹងការរួមសុខរួមទុក្ខ និងតម្រូវការកសាងរដ្ឋមួយឱ្យរឹងមាំ អ្នកដឹកនាំគណបក្សប្រជាជនបានអភិវឌ្ឍគណៈបក្សប្រជាជនប្រកបដោយវិន័យ និងមូលគ្នាជាធ្លុងមួយ។ កត្តាទាំងនេះបាននាំឱ្យគណបក្សប្រជាជនប្រែក្លាយជាស្ថាប័នមួយដែលមានប្រសិទ្ធភាពក្នុងការសម្រេចចិត្តរួមគ្នា ដែលជាកត្តាអនុញ្ញាតឱ្យគណបក្សនេះបញ្ចៀសនូវបញ្ហាស្មុគស្មាញ ដូចជាជំលោះផ្ទៃក្នុងជុំវិញបញ្ហានយោបាយ និងការជ្រើសតាំងអ្នកដឹកនាំ។

ដំណើរការនៃការតែងតាំងបណ្ឌិត ហ៊ុន ម៉ាណែត ជាបេក្ខភាពនាយករដ្ឋមន្ត្រីនាពេលអនាគត គឺបង្ហាញពីស្ថាប័ននីយកម្មរបស់គណបក្សប្រជាជនកម្ពុជា។ ជាការពិត សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ជាអ្នកចាប់ផ្តើមការស្នើតែងតាំងនេះ ប៉ុន្តែការសម្រេចចិត្តចុងក្រោយបំផុត ត្រូវបានធ្វើឡើងដោយគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា។ ទោះបីជាការជ្រើសតាំងនេះ បានឆ្លុះបញ្ចាំងពីស្ថាប័នីយកម្មរបស់គណៈបក្ស ប៉ុន្តែវាក៏ជាការឆ្លុះបញ្ចាំងពីទំនុកចិត្តរបស់គណបក្សប្រជាជនទៅលើបណ្ឌិត ហ៊ុន ម៉ាណែត ផងដែរ។ យើងសង្កេតឃើញថា នៅក្នុងអំឡុងពេលពីរទសវត្សរ៍ចុងក្រោយកម្ពុជាមានការអភិវឌ្ឍធនធានមនុស្សប្រកបដោយសមត្ថភាពដែលអាចផ្តល់បេក្ខភាពដឹកនាំប្រទេសជាច្រើនរូប។ ប៉ុន្តែ ក្នុងចំណោមបេក្ខភាពជំនាន់ក្រោយទាំងនេះ អ្នកដឹកនាំគណបក្សប្រជាជនក៏ដូចជាមហាជនខ្មែរទូទៅយល់ឃើញថា មិនមានជម្រើសណាដែលស័ក្តិសម ជាងការបោះឆ្នោតជ្រើសរើសបណ្ឌិត ហ៊ុន ម៉ាណែត ជាបេក្ខភាពនាយករដ្ឋមន្ត្រីដើម្បីបន្តដឹកនាំកម្ពុជានៅក្នុងដំណាក់កាលនៃការប្រែប្រួលយ៉ាងខ្លាំងនៃបរិបទក្នុងប្រទេស និងសាកលនោះទេ។

ប្រព័ន្ធអន្តរជាតិបានងាកចេញពីពិភពឯកប៉ូល នៅក្រោមអំណាចនៃការដឹកនាំរបស់អាមេរិក ទៅកាន់ពិភពពហុប៉ូលក្រោមឥទ្ធិពលរបស់ចិន អាមេរិក រុស្ស៊ី និងសហភាពអឺរ៉ុប។ ចលនានេះបានកំណត់ទម្រង់នៃភូមិសាស្ត្រនយោបាយសាកលក្នុងលក្ខណៈមួយដែលទាមទារឱ្យកម្ពុជាមានមេដឹកនាំដែលមានការគិតប្រកបដោយយុទ្ធសាស្ត្រ និងតាមក្បួនខ្នាតយោធាទំនើប។ ជាអ្នកដែលបានបញ្ចប់ការសិក្សាពីបណ្ឌិតសភាយោធាអាមេរិកនៅ West Point ជាអ្នកដែលមានបទពិសោធន៍ដឹកនាំយោធាក្នុងសមរភូមិ និងជាអ្នកមានទេពកោសល្យក្នុងការចរចាការទូត ដូចដែលបណ្ឌិត ហ៊ុន ម៉ាណែត បានបង្ហាញក្នុងតួនាទីរបស់លោកក្នុងខណៈដែលប្រទេសកម្ពុជាកំពុងមានជម្លោះព្រំដែនជាមួយប្រទេសថៃ បណ្ឌិត ហ៊ុន ម៉ាណែត គឺជាបេក្ខភាពដែលស័ក្តិសមបំផុតក្នុងការបន្តដឹកនាំកម្ពុជា នៅក្នុងស្ថានការណ៍នៃការប្រែប្រួលយុទ្ធសាស្ត្រភូមិសាស្ត្រនយោបាយបែបនេះ។

បន្ថែមពីលើនេះទៀត សេដ្ឋកិច្ចសាកលលោកកំពុងជួបនូវការផ្លាស់ប្តូរប្រកបដោយភាពស្មុគស្មាញ ដោយសារអន្តរទំនាក់ទំនង និងដំណើរឈានមកដល់នៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថលជាស្នូល។ ដើម្បីឱ្យសេដ្ឋកិច្ចមានលទ្ធភាពបន្តលូតលាស់ក្នុងបរិយាកាសដែលកំពុងប្រែប្រួល និងមានការប្រកួតប្រជែងខ្ពស់បែបនេះ ប្រទេសកម្ពុជាត្រូវការអ្នកដឹកនាំដែលមានចំណេះដឹងខ្ពស់ពីវិស័យសេដ្ឋកិច្ចទំនើប។ ជាមួយនឹងសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ចពីសាកលវិទ្យាល័យ New York និងសញ្ញាបត្របណ្ឌិតផ្នែកសេដ្ឋកិច្ចពីសាកលវិទ្យាល័យ Bristol បណ្ឌិត ហ៊ុន ម៉ាណែត មានគុណវុឌ្ឍិ និងបំណិនគ្រប់គ្រាន់ក្នុងការដឹកនាំកម្ពុជាក្នុងរបៀបមួយ ដែលអាចទាញយកប្រយោជន៍បានយ៉ាងប្រសើរពីសាកលភាវូបនីយកម្មសេដ្ឋកិច្ច និងអាចដាក់ចេញនូវយុទ្ធសាស្ត្រសម្រាប់ការប្រឈមណាមួយដែលអាចកើតមានឡើង។

ខ្ញុំក៏សូមលើកបញ្ជាក់ផងដែរថា ខ្ញុំជំទាស់នឹងអ្នកនយោបាយប្រឆាំងដែលថា បណ្ឌិត ហ៊ុន ម៉ាណែត ទទួលបានសញ្ញាបត្រកម្រិតលេខពីរពីបរទេស។ ការថ្លែងបែបនេះ គឺជាការមួលបង្កាច់ទាំងស្រុង។ ខ្ញុំគឺជាសាស្ត្រាចារ្យខ្មែរមួយរូបដែលបង្រៀននៅសាកលវិទ្យាល័យនៅសហរដ្ឋអាមេរិកជិត ២០ឆ្នាំហើយ ខ្ញុំមិនធ្លាប់បានឮ ឬក៏ជួបប្រទះបញ្ហាដែលថាសាកលវិទ្យាល័យនៅអាមេរិកមានសញ្ញាបត្រពីរលំដាប់នោះទេ ហើយការថ្លែងបែបនេះគឺពិតជាមានចេតនាបន្ទោសបង្អាប់សមត្ថភាពកូនខ្មែរ។ តាមពិត និស្សិតខ្មែរដែលរៀននៅបរទេសមានសមត្ថ-ភាពខ្ពស់ជាងនិស្សិតអាមេរិកមួយចំនួនទៀត។ ឧទាហរណ៍ និស្សិតខ្មែររបស់ខ្ញុំម្នាក់ (ឈ្មោះ អ៊ុង លីម៉េង) មកពីសាកលវិទ្យាល័យអាមេរិកាំងភ្នំពេញ (AUPP) កំពុងសិក្សាថ្នាក់បណ្ឌិត ជានិស្សិតឆ្នើមម្នាក់នៅសាកលវិទ្យាល័យ Northern Illinois ដែលខ្ញុំកំពុងបង្រៀនបច្ចុប្បន្ន។

ក្នុងរយៈពេលជាងមួយទសវត្សរ៍នៃការឈានជើងប្រឡូកក្នុងការបម្រើជាតិ បណ្ឌិត ហ៊ុន ម៉ាណែត មានភាពសកម្ម និងជោគជ័យក្នុងការការពារអធិបតេយ្យជាតិខ្មែរ និងបានចូលរួមដោះស្រាយវិបត្តិជាច្រើន រួមមានគ្រោះមហន្តរាយដែលបង្កឡើងដោយជំងឺកូវីដ១៩ ហើយនេះគឺជាគុណសម្បត្តិដែលដែលប្រទេសកម្ពុជាត្រូវការ។ លើសពីនេះទៀត បណ្ឌិត ហ៊ុន ម៉ាណែត មានកេរ្តិ៍ឈ្មោះស្អាតស្អំ។ នេះជាគុណសម្បត្តិដ៏សំខាន់សម្រាប់អ្នកបន្តវេនដឹកនាំក្នុងបរិបទសង្គមដែលពោរពេញដោយពាក្យចចាមអារាមអំពីអំពើពុករលួយ (ទោះពិតក្តី មិនពិតក្តី) មានកម្រិតខ្ពស់។

ជាការពិត ការវិនិច្ឆ័យចុងក្រោយលើការជ្រើសរើសបណ្ឌិត ហ៊ុន ម៉ាណែត ជាអ្នកបន្តវេនដឹកនាំនាពេលអនាគតគឺជាតួនាទីរបស់ប្រវត្តិសាស្ត្រ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងពេលនេះ សញ្ញាណទាំងអស់បានបង្ហាញឱ្យឃើញថា ការបោះឆ្នោតជ្រើសរើសបណ្ឌិត ហ៊ុន ម៉ាណែត ដើម្បីបន្តដឹកនាំកម្ពុជាជាជម្រើសដ៏ប្រសើរបំផុតសម្រាប់ប្រទេសមួយនេះ។

Cambodia Development Center
Cambodia Development Center (@cd.centerkh)
Cambodia Development Center
Cambodia Development Center (t.me/cdcenterkh)
The Kampus Building, Unit 1D, Street 93, Sangkat Tonle Bassac, Khan Chamkarmon
info@cd-center.org | (+855) 10 950 456 www.cd-center.org